ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១៣៣៥ ស.ហ.ប្រក

# ប្រកាសរួម
## ស្តីពី
## ការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ ដោយក្រសួងសុខាភិបាល

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**រដ្ឋមន្ត្រី ក្រសួងសុខាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៦/០២ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងឱសថ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.

- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣៧ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងឱសថ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផល ទំនិញ និងសេវា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១០០/១០ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ០០៤៤ អនក្រ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ស្តីពីទិដ្ឋាការ-បញ្ជិកាឱសថ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៩៤ អនក្រ.បក ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០២ ស្តីពីបែបបទ និងល័ក្ខខ័ណ្ឌនៃការអនុញ្ញាតឱ្យជនបរទេសជាអ្នកវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ ប្រកបវិជ្ជាជីវៈឯកជនក្នុងព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៣៣ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៥ ស្តីពីការផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ១២២ អនក្រ.បក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៨ ស្តីពីការគ្រប់គ្រងគ្រឿងសម្អាង
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៩ ស្តីពីការកែសម្រួលមាត្រា៦ នៃអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលតារាងពន្ធតែមប្រិសាពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់និងឆ្លើយតបការឆ្លងរាលដាលជាអន្តរជាតិនៃជំងឺនៅតាមច្រកចេញចូល
- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ

- បានឃើញសេចក្តីសម្រេចលេខ ០៩៧ ត.ប.អវ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ដោយបានសម្រេចកំណត់ការបង់ថ្លៃរបស់និស្សិតសម្រាប់រៀបចំការប្រឡងថ្នាក់ជាតិជ្រើសរើសនិស្សិតចូលរៀនកម្រិតបរិញ្ញាបត្រ និងបរិញ្ញាបត្ររងក្នុងវិស័យសុខាភិបាល ចំនួន ១២០.០០០(ដប់ពីរម៉ឺន) រៀល សម្រាប់និស្សិតម្នាក់
- បានឃើញសេចក្តីសម្រេចលេខ ៩០ សជណ.អវ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ដោយបានសម្រេចកំណត់ការបង់ថ្លៃរបស់និស្សិត សម្រាប់ការប្រឡងចេញថ្នាក់ជាតិក្នុងវិស័យសុខាភិបាល ចំនួន ១០០ ០០០(ដប់ម៉ឺន) រៀល សម្រាប់និស្សិតម្នាក់
- បានឃើញប្រកាសរួមលេខ ៨៦៨ ឧរថ.ប្រក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១០ ស្តីពីការអនុវត្តន៍ និងការរៀបចំសម្របសម្រួលស្ថាប័នកិច្ចនៃប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពម្ហូបអាហារ ចាប់កសិដ្ឋានផលិតផល ដល់តុបរិភោគ
- បានឃើញប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់
- បានឃើញប្រកាសលេខ ១៨៩០ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីនីតិវិធីនៃការគ្រប់គ្រងរជ្ជទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញសារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសុខាភិបាល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១ .-**

អនុញ្ញាតឱ្យក្រសួងសុខាភិបាល អនុវត្តការប្រមូលចំណូលពីកម្រៃសេវាសាធារណៈ និងពិន័យអន្តរការណ៍ជាប្រាក់ ដើម្បីជាគុណប្រយោជន៍ដល់ថវិកាជាតិ។

**ប្រការ២ .-**

សេវាសាធារណៈ ដែលផ្តល់ដោយក្រសួងសុខាភិបាល ត្រូវបានរៀបចំជាកម្រងសេវាសាធារណៈ ដែលមានរាយលម្អិតអំពីតម្លៃសេវា រយៈពេលអតិបរមានៃការផ្តល់សេវា និងសុពលភាព ទៅតាមប្រភេទសេវាសាធារណៈនីមួយៗ។

កម្រងសេវាសាធារណៈរបស់ក្រសួងសុខាភិបាល ត្រូវបានរៀបចំចែកចេញជាពីរផ្នែក ដោយផ្នែកទី១ ជាកម្រងសេវាសាធារណៈដែលអនុវត្តដោយរដ្ឋបាលកណ្តាលក្រសួងសុខាភិបាល និងផ្នែកទី២ ជាកម្រងសេវាសាធារណៈដែលអនុវត្តដោយមន្ទីរសុខាភិបាលរាជធានី ខេត្ត ដូចមានចែងក្នុងឧបសម្ព័ន្ធ១ និងឧបសម្ព័ន្ធ២ ដែលភ្ជាប់នឹងប្រកាសរួមនេះ។

**ប្រការ៣ .-**

ក្រសួងសុខាភិបាល ត្រូវកំណត់នីតិវិធីអនុវត្តសម្រាប់ការពិន័យអន្តរការណ៍ជាប្រាក់ដោយរដ្ឋបាលកណ្តាលក្រសួងសុខាភិបាល និងមន្ទីរសុខាភិបាលរាជធានី ខេត្ត ជាពិសេសត្រូវទុករយៈពេលមួយសមស្របសម្រាប់ការបង់ប្រាក់ពិន័យរបស់អ្នកប្រព្រឹត្តល្មើស ស្របតាមប្រភេទបទល្មើសដែលមានចែងក្នុង ÷

- ច្បាប់ស្តីពីការប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ
- ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងឱសថ
- ច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផលទំនិញ និងសេវា
- អនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់និងឆ្លើយតបការឆ្លងរាលដាលជាអន្តរជាតិនៃជំងឺនៅតាមច្រកចេញចូល
- អនុក្រឹត្យលេខ ១៣៣ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៥ ស្តីពីការផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ

ប្រភេទបទល្មើស និងកម្រិតទឹកប្រាក់ពិន័យទៅតាមប្រភេទបទល្មើសនីមួយៗ ត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធ៣ ដែលភ្ជាប់នឹងប្រកាសរួមនេះ។

**ប្រការ៤ .-**

ក្រសួងសុខាភិបាល ត្រូវផ្សព្វផ្សាយជាសាធារណៈ ជាពិសេសនៅកន្លែងផ្តល់សេវាសាធារណៈ ត្រូវបិទផ្សាយប្រកាសរួម, កម្រងសេវាសាធារណៈ និងតារាងពិន័យអន្តរការណ៍ជាប្រាក់ ដែលរួមមានឧបសម្ព័ន្ធ១ ឧបសម្ព័ន្ធ២ និងឧបសម្ព័ន្ធ៣ នៃប្រកាសរួមនេះ ព្រមទាំងនីតិវិធី និងលក្ខខណ្ឌសម្រាប់ការផ្តល់សេវាដែលមានការពាក់ព័ន្ធ។

នៅកន្លែងផ្តល់សេវាសាធារណៈ ត្រូវរៀបចំឱ្យមានកន្លែងទទួលបណ្តឹងតវ៉ា ដែលអាចកើតមានឡើងជាយថាហេតុ ជាពិសេសក្នុងករណីមានការអនុវត្តខុសពីស្តង់ដារសេវា ឬ មានការយកកម្រៃលើសការកំណត់ ឬ មានការយឺតយ៉ាវក្នុងការផ្តល់សេវាសាធារណៈជាដើម។

ការទទួលបណ្តឹងតវ៉ារបស់អតិថិជន ត្រូវមានការបើកទូលាយដោយមានដាក់លេខទូរស័ព្ទ សារអេឡិចត្រូនិក ប្រអប់សំបុត្រ និងផ្តល់ឱកាសឱ្យអតិថិជនអាចធ្វើទំនាក់ទំនង ឬ ប្តឹងទៅរដ្ឋមន្ត្រីក្រសួងសុខាភិបាល ឬ អង្គភាពប្រឆាំងអំពើពុករលួយផងដែរ។

**ប្រការ៥ .-**

ក្រសួងសុខាភិបាល ត្រូវកំណត់ទីតាំងជាក់លាក់ និងមានមន្ត្រីប្រចាំការដែលមានលក្ខណៈជាច្រកចេញចូលតែមួយនៅទីតាំងដែលបានកំណត់ ដើម្បីទទួលបម្រើសេវាជូនអតិថិជនឱ្យបានទាន់ពេលវេលា តាមការកំណត់។

**ប្រការ៦ .-**

រាល់ការទទួលប្រាក់ចំណូលដោយផ្ទាល់ជាសាច់ប្រាក់ ឬ ជាមូលប្បទានប័ត្រ លើការប្រមូលចំណូលពីកម្រៃសេវាសាធារណៈ និងការពិន័យជាប្រាក់ ត្រូវប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ដែលបើកផ្តល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្របតាមប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ និងសារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ៧ .-**

រដ្ឋបាលកណ្តាលក្រសួងសុខាភិបាល និងមន្ទីរសុខាភិបាល រាជធានី ខេត្ត ត្រូវទទួលខុសត្រូវប្រាក់កាសលើប្រាក់ចំណូលដែលប្រមូលបាន បង់ប្រាក់ចំណូល និងធ្វើសលាកប័ត្រចំណូលថវិកាជាតិ ព្រមទាំងចុះកិច្ចបញ្ជិកាគណនេយ្យស្តីពីកិច្ចប្រតិបត្តិការចំណូល និងកត់ត្រាតាមដានប្រាក់ចំណូលនៅក្នុងជំពូក គណនី អនុគណនី នៃមាតិកាចំណូលថវិកា។

**ប្រការ៨ .-**

ក្រសួងសុខាភិបាល ត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តចំណូលប្រចាំខែ និងប្រចាំឆ្នាំ ផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

មន្ទីរសុខាភិបាលរាជធានី ខេត្ត ត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តចំណូលប្រចាំខែ និងប្រចាំឆ្នាំ ផ្ញើជូនក្រសួងសុខាភិបាល និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

**ប្រការ៩ .-**

កម្រងសេវាសាធារណៈដូចមានចែងក្នុងឧបសម្ព័ន្ធ១ និងឧបសម្ព័ន្ធ២ ព្រមទាំងការពិន័យជាប្រាក់ដែលមានចែងក្នុងឧបសម្ព័ន្ធ៣ នៃប្រកាសរួមនេះ អាចកែប្រែបានតាមការចាំបាច់តាមរយៈប្រកាសរួមរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល។

**ប្រការ១០ .-**

ត្រូវបាននិរាករណ៍ប្រកាសរួមទាំងឡាយដូចខាងក្រោម ÷

ប្រកាសរួមលេខ ៩៩៣ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងសុខាភិបាល

- ប្រកាសរួមលេខ ១៤៣២ សហវ.ប្រក ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការកែប្រែកម្រងសេវាសាធារណៈនៃតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ ៩៩៣ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងសុខាភិបាល
- ប្រកាសរួមលេខ ០០៥ សហវ.ប្រក ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៦ ស្តីពីការកែប្រែកម្រងសេវាសាធារណៈនៃតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ ១៤៣២ សហវ.ប្រក ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៤។

**ប្រការ១១ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសរួមនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១២ .-**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសុខាភិបាល ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃទី.០១... ខែ.ធ្នូ.......... ឆ្នាំ២០១៦ តទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៦

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

រដ្ឋមន្ត្រី
ក្រសួងសុខាភិបាល

ម៉ម_ប៊ុនហេង

កន្លែងទទួល :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- សាលារាជធានី ខេត្ត
- ដូចប្រការ១២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ១ ភ្ជាប់នឹងប្រកាសរួមលេខ.១៣៥៤.. សហវ.ប្រក ចុះថ្ងៃទី..១៨.... ខែ.វិច្ឆិកា... ឆ្នាំ២០១៦

ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ ដោយក្រសួងសុខាភិបាល

កម្រងសេវាសាធារណៈដែលអនុវត្តដោយរដ្ឋបាលកណ្តាលក្រសួងសុខាភិបាល

| ល.រ | បរិយាយ | តម្លៃឯកតា នៃសេវា | រយៈពេលអតិបរមា សម្រាប់ការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ១ | ការផ្តល់សេចក្តីសម្រេចអនុញ្ញាតដល់គ្រឹះស្ថានផលិតឱសថ ចំពោះ ÷ | | | |
| | - ការបើកថ្មី | ៤ ០០០ ០០០ រៀល | ២០ថ្ងៃ | ២ឆ្នាំ |
| | - ការប្តូរទីតាំង | ៤ ០០០ ០០០ រៀល | ២០ថ្ងៃ | ២ឆ្នាំ |
| | - ការប្តូរឱសថការី ឬ ប្តូរឈ្មោះគ្រឹះស្ថានផលិតឱសថ ឬប្តូរម្ចាស់ទុន | ២ ០០០ ០០០ រៀល | ២០ថ្ងៃ | ២ឆ្នាំ |
| | - ការផ្លាស់ប្តូរ ឬ បន្ថែមខ្សែសង្វាក់ផលិតកម្ម ឬឃ្លាំងស្តុក ឬមន្ទីរពិសោធន៍ | ២ ០០០ ០០០ រៀល | ២០ថ្ងៃ | ២ឆ្នាំ |
| | - ការបើកសាខាគ្រឹះស្ថានផលិតឱសថ | ៤ ០០០ ០០០ រៀល | ២០ថ្ងៃ | ២ឆ្នាំ |
| | - ការផ្លាស់ប្តូរទីតាំងសាខាគ្រឹះស្ថានផលិតឱសថ | ៤ ០០០ ០០០ រៀល | ២០ថ្ងៃ | ២ឆ្នាំ |
| ២ | ការផ្តល់វិញ្ញាបនបត្រ GMP | ២ ០០០ ០០០ រៀល | ៥០ថ្ងៃ | ២ឆ្នាំ |
| ៣ | ការផ្តល់លិខិតអនុញ្ញាតដល់ការិយាល័យតំណាងគ្រឹះស្ថានផលិតឱសថ ចំពោះការបើក ឬ ផ្លាស់ប្តូរទីតាំង | ៦០០ ០០០ រៀល | ២០ថ្ងៃ | ២ឆ្នាំ |
| ៤ | ការផ្តល់សេចក្តីសម្រេចអនុញ្ញាតឱ្យផ្សព្វផ្សាយពាណិជ្ជកម្ម ចំពោះ ÷ | | | |
| ៤.១ | ឱសថ : | | | |
| | - តាមទស្សនាវដ្តី ឬ សារព័ត៌មាន ឬគេហទំព័រ ឬបណ្តាញសង្គម | ៦០០ ០០០ រៀល | ២០ថ្ងៃ | ៦ខែ |
| | - តាមទូរទស្សន៍(ប៉ុស្តិ៍) ឬ វិទ្យុ ឬ TV Screen Show | ៦០០ ០០០ រៀល | ២០ថ្ងៃ | ៦ខែ |
| | - តាមខិត្តប័ណ្ណ ឬប្រតិទិន ឬ សម្ភារប្រើប្រាស់ ឬ សម្ភារការិយាល័យ | ៦០០ ០០០ រៀល | ២០ថ្ងៃ | ១ឆ្នាំ |
| | - តាមរយៈការធ្វើសិក្ខាសាលា ឬ ការប្រជុំផ្សេងៗ ឬ ស្តង់ផ្សព្វផ្សាយ | ៦០០ ០០០ រៀល | ១០ថ្ងៃ | ១ខែ |

| ល.រ | បរិយាយ | តម្លៃឯកតា នៃសេវា | រយៈពេលអតិបរមា សម្រាប់ការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ៤.២ | និលថប៉ប៉នសុខភាព ឬ និលថបូរាណ ឬ គ្រឿងសម្អាង ឬ ឧបករណ៍បរិក្ខារពេទ្យ ឬ ប្រតិករ ឬ ផលិតផលជំនួយសុខភាពប្រើលើខ្លួនមនុស្សផ្នែកខាងក្រៅ : | | | |
| | - តាមទស្សនាវដ្តី ឬ សារព័ត៌មាន ឬ គេហទំព័រ ឬ បណ្តាញសង្គម ឬ Poster (ទំហំក្រដាស A4) | ៦០០ ០០០ រៀល | ២០ថ្ងៃ | ៦ខែ |
| | - តាមទូរទស្សន៍(ប៉ុស្តិ៍) ឬ វិទ្យុ ឬ TV Screen Show | ៦០០ ០០០ រៀល | ២០ថ្ងៃ | ៦ខែ |
| | - តាម Poster Stand ឬ ផ្លាកយីហោ ឬ បដា ឬ មធ្យោបាយដឹកជញ្ជូន ឬ ប្រអប់ភ្លើងនៅតាមទីសាធារណៈ ឬ ផ្ទាំងក្រដាស់តាមទីសាធារណៈ ឬ ផ្ទាំងរូបតាំងបញ្ឈរ ឬ ផ្ទាំងប៉ាណូដាក់តាមទីសាធារណៈ | ១ ០០០ ០០០ រៀល | ២០ថ្ងៃ | ៦ខែ |
| | - តាមខិត្តប័ណ្ណ ប័ណ្ណប្រកាស ឬ ប្រតិទិន ឬ សម្ភារប្រើប្រាស់ផ្សេងៗ ឬ សម្ភារការិយាល័យ | ៦០០ ០០០ រៀល | ២០ថ្ងៃ | ១ឆ្នាំ |
| | - តាមរយៈការធ្វើសិក្ខាសាលា ឬ ការប្រជុំផ្សេងៗ ឬ ស្តង់ផ្សព្វផ្សាយពាណិជ្ជកម្ម | ៦០០ ០០០ រៀល | ១០ថ្ងៃ | ១ខែ |
| ៤.៣ | ផលិតផលចិញ្ចឹមកុមារ និងទារក : | | | |
| | - តាមទស្សនាវដ្តី ឬ សារព័ត៌មាន ឬ ឯកសារផ្សព្វផ្សាយផ្សេងៗ ឬ Poster Stand ឬ សម្ភារផ្សព្វផ្សាយផ្សេងៗ ឬ មធ្យោបាយផ្សព្វផ្សាយផ្សេងៗ ក្នុងមួយប្រភេទផលិតផល | ៦០០ ០០០ រៀល | ២០ថ្ងៃ | ៦ខែ |
| | - តាមទូរទស្សន៍ ឬ វិទ្យុ ក្នុងមួយប្រភេទផលិតផល | ៦០០ ០០០ រៀល | ២០ថ្ងៃ | ៦ខែ |
| | - តាមខិត្តប័ណ្ណ ឬ ប្រតិទិន ក្នុងមួយប្រភេទផលិតផល | ៦០០ ០០០ រៀល | ២០ថ្ងៃ | ១ឆ្នាំ |
| | - តាមផ្ទាំងប៉ាណូ ឬ ប្រអប់ភ្លើងនៅតាមទីសាធារណៈ ក្នុងមួយប្រភេទផលិតផល | ១ ០០០ ០០០ រៀល | ២០ថ្ងៃ | ១ឆ្នាំ |
| | - តាមការតាំងពិព័រណ៍ ឬ តាំងបង្ហាញផ្សេងៗ ក្នុងមួយទីតាំង ឬ មួយកន្លែង | ៨០០ ០០០ រៀល | ២០ថ្ងៃ | តាមការស្នើសុំ (មិនលើសពី ៣០ថ្ងៃ) |
| ៤.៤ | ផលិតផលចិញ្ចឹមកុមារ និងទារក តាមការធ្វើសិក្ខាសាលា ឬ ប្រជុំផ្សេងៗ | | | |
| | - អ្នកចូលរួមរហូតដល់ 100នាក់ ក្នុងមួយលើក | ៦០០ ០០០ រៀល | ២០ថ្ងៃ | តាមការស្នើសុំ (មិនលើសពី ៣០ថ្ងៃ) |
| | - អ្នកចូលរួមច្រើនជាង100នាក់ ក្នុងមួយលើក | ១ ០០០ ០០០ រៀល | ២០ថ្ងៃ | តាមការស្នើសុំ (មិនលើសពី ៣០ថ្ងៃ) |

| ល.រ | បរិយាយ | តម្លៃឯកតា នៃសេវា | រយៈពេលអតិបរមា សម្រាប់ការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ៤.៥ | បិទស្លាកសញ្ញាផលិតផល ឬ បោះពុម្ពជាប់កំប៉ុង ឬ ដប ក្នុងមួយប្រភេទផលិតផល | ៨០០ ០០០ រៀល | ២០ថ្ងៃ | ៣ឆ្នាំ |
| ៥ | ផ្តល់គំរូសាកផលិតផលអាហារសម្រាប់ចិញ្ចឹមទារក និងកុមារជូនគ្រូពេទ្យជំនាញ ដើម្បីស្វែងយល់ពីផលិតផល ក្នុងមួយប្រភេទផលិតផល | ១ ២០០ ០០០ រៀល | ២០ថ្ងៃ | ៦ខែ |
| ៦ | ការផ្តល់សេចក្តីសម្រេចអនុញ្ញាតឱ្យចុះពាណិជ្ជនាមឱសថ | ២៨០ ០០០ រៀល | ៣០ថ្ងៃ | ១ឆ្នាំ |
| ៧ | ការផ្តល់វិញ្ញាបនបត្រឱ្យចុះបញ្ជីគ្រឹះស្ថានផលិតឱសថនៅបរទេស | ៤ ៨០០ ០០០ រៀល | ១២០ថ្ងៃ | ៥ឆ្នាំ |
| ៨ | ការផ្តល់វិញ្ញាបនបត្រឱ្យចុះទិដ្ឋាការ-បញ្ជិកា ចំពោះ ÷ | | | |
| | - ឱសថ | ១ ០០០ ០០០ រៀល | ២៧០ថ្ងៃ | ៥ឆ្នាំ |
| | - ឧបករណ៍បរិក្ខារពេទ្យ ឬ ប្រតិករ ឬ ផលិតផលជំនួយសុខភាពប្រើលើខ្លួនមនុស្សផ្នែកខាងក្រៅ ឬ ឱសថបុរាណ ឬ ឱសថបំប៉នសុខភាព | ៤០០ ០០០ រៀល | ១០០ថ្ងៃ | ៣ឆ្នាំ |
| ៩ | ការផ្តល់វិញ្ញាបនបត្រឱ្យចុះប្រវេទន៍គ្រឿងសម្អាង | ៨០ ០០០ រៀល | ១៥ថ្ងៃ | ២ឆ្នាំ |
| ១០ | ការផ្តល់សេចក្តីសម្រេចអនុញ្ញាតដល់គ្រឹះស្ថានអាហារ៍ណ នីហារ៍ណឱសថ គ្រឿងសម្អាង ចំពោះ ÷ | | | |
| | - ការបើកថ្មី | ១ ២០០ ០០០ រៀល | ១៥ថ្ងៃ | ២ឆ្នាំ |
| | - ប្តូរទីតាំង | ១ ២០០ ០០០ រៀល | ១៥ថ្ងៃ | ២ឆ្នាំ |
| | - ការបើកសាខា | ៨០០ ០០០ រៀល | ១៥ថ្ងៃ | ២ឆ្នាំ |
| | - ប្តូរទីតាំងសាខា | ៨០០ ០០០ រៀល | ១៥ថ្ងៃ | ២ឆ្នាំ |
| | - ផ្លាស់ប្តូរឱសថការី ឬ ប្តូរឈ្មោះគ្រឹះស្ថានអាហារ៍ណ នីហារ៍ណឱសថ គ្រឿងសម្អាង ឬ ប្តូរម្ចាស់ថ្មី | ៨០០ ០០០ រៀល | ១៥ថ្ងៃ | ២ឆ្នាំ |
| ១១ | ការផ្តល់លិខិតអនុញ្ញាតឱ្យនាំចូលឱសថ ឧបករណ៍បរិក្ខារពេទ្យ និងគ្រឿងសម្អាង | ២០០ ០០០ រៀល | ១០ថ្ងៃ | ១ខែ |
| ១២ | ការផ្តល់លិខិតអនុញ្ញាតឱ្យនាំចូលឱសថញៀន និងឱសថព្យាបាលផ្លូវចិត្ត | ២០០ ០០០ រៀល | ២០ថ្ងៃ | ៨ខែ |
| ១៣ | ការផ្តល់លិខិតអនុញ្ញាតនាំចេញឱសថ ឧបករណ៍បរិក្ខារពេទ្យ និងគ្រឿងសម្អាង | ២០០ ០០០ រៀល | ១០ថ្ងៃ | ៣ខែ |

| ល.រ | បរិយាយ | តម្លៃឯកតានៃសេវា | រយៈពេលអតិបរមាសម្រាប់ការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ១៤ | ការផ្តល់សេចក្តីសម្រេចអនុញ្ញាតដល់មជ្ឈមណ្ឌលថែរក្សាសម្ផស្ស ចំពោះ ÷ | | | |
| | - ការបើកថ្មី | ៨០០ ០០០ រៀល | ១៥ថ្ងៃ | ២ឆ្នាំ |
| | - ការបើកសាខា | ៦០០ ០០០ រៀល | ១៥ថ្ងៃ | ២ឆ្នាំ |
| | - ប្តូរទីតាំង (គ្រឹះស្ថាន និងសាខា) | ៦០០ ០០០ រៀល | ១៥ថ្ងៃ | ២ឆ្នាំ |
| | - ប្តូរអ្នកទទួលខុសត្រូវបច្ចេកទេសថែរក្សាសម្ផស្ស ឬ ប្តូរម្ចាស់ទុន ឬ ប្តូរឈ្មោះមជ្ឈមណ្ឌលថែរក្សាសម្ផស្ស | ៦០០ ០០០ រៀល | ១៥ថ្ងៃ | ២ឆ្នាំ |
| ១៥ | ការផ្តល់វិញ្ញាបនបត្របញ្ជាក់អនាម័យផលិតផលចំណីអាហារលើការពិនិត្យរកមេរោគ (Hygience Certificate) | ៥០០ ០០០ រៀល | ៤០ថ្ងៃ | ២ឆ្នាំ |
| ១៦ | ការផ្តល់វិញ្ញាបនបត្រអនុញ្ញាតដាក់លក់ផលិតផលចំណីអាហារ | ៦០០ ០០០ រៀល | ៣០ថ្ងៃ | ១ឆ្នាំ |
| ១៧ | ការផ្តល់វិញ្ញាបនបត្រអនាម័យចំណីអាហារ លើការពិនិត្យរកមេរោគ ជាតិពុល និងលោហៈធ្ងន់ (Health Certificate of Food) | ៦០០ ០០០ រៀល | ៣០ថ្ងៃ | ១ឆ្នាំ |
| ១៨ | ការផ្តល់វិញ្ញាបនបត្របញ្ជាក់គម្រិតអនាម័យតាមភោជនីយដ្ឋាន (តាមគោលការណ៍ស្ម័គ្រចិត្ត) | | | |
| | - Logo A | ៨០០ ០០០ រៀល | ៣០ថ្ងៃ | ២ឆ្នាំ |
| | - Logo B | ៦០០ ០០០ រៀល | ៣០ថ្ងៃ | ២ឆ្នាំ |
| | - Logo C | ៤០០ ០០០ រៀល | ៣០ថ្ងៃ | ២ឆ្នាំ |
| ១៩ | ការផ្តល់លិខិតអនុញ្ញាតដល់បន្ទប់ព្យាបាលជម្ងឺមាត់-ធ្មេញ ចំពោះ ÷ | | | |
| | - ការបើកថ្មី | ៤ ០០០ ០០០ រៀល | ២០ថ្ងៃ | ៤ឆ្នាំ |
| | - ការផ្ទេរអ្នកទទួលខុសត្រូវ | ២ ០០០ ០០០ រៀល | ២០ថ្ងៃ | |
| | - ការប្តូរទីតាំង | ៣ ០០០ ០០០ រៀល | ២០ថ្ងៃ | ៤ឆ្នាំ |
| ២០ | ការផ្តល់លិខិតអនុញ្ញាតដល់បន្ទប់ពិសោធន៍វេជ្ជសាស្ត្រ ចំពោះ ÷ | | | |
| | - ការបើកថ្មី | ៤ ០០០ ០០០ រៀល | ២០ថ្ងៃ | ៤ឆ្នាំ |
| | - ការផ្ទេរអ្នកទទួលខុសត្រូវ | ២ ០០០ ០០០ រៀល | ២០ថ្ងៃ | |
| | - ការប្តូរទីតាំង | ៣ ០០០ ០០០ រៀល | ២០ថ្ងៃ | ៤ឆ្នាំ |

| ល.រ | បរិយាយ | តម្លៃឯកតា នៃសេវា | រយៈពេលអតិបរមា សម្រាប់ការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ២១ | ការផ្តល់លិខិតអនុញ្ញាតដល់មន្ទីរសម្ភព ចំពោះ ÷ | | | |
| | - ការបើកថ្មី | ៤ ០០០ ០០០ រៀល | ២០ថ្ងៃ | ៤ឆ្នាំ |
| | -ការផ្ទេរអ្នកទទួលខុសត្រូវ | ២ ០០០ ០០០ រៀល | ២០ថ្ងៃ | |
| | - ការប្តូរទីតាំង | ៣ ០០០ ០០០ រៀល | ២០ថ្ងៃ | ៤ឆ្នាំ |
| ២២ | ការផ្តល់លិខិតអនុញ្ញាតដល់មន្ទីរសម្រាកព្យាបាល ចំពោះ ÷ | | | |
| | - ការបើកថ្មី | ៤ ០០០ ០០០ រៀល | ២០ថ្ងៃ | ៤ឆ្នាំ |
| | -ការផ្ទេរអ្នកទទួលខុសត្រូវ | ២ ០០០ ០០០ រៀល | ២០ថ្ងៃ | |
| | - ការប្តូរទីតាំង | ៣ ០០០ ០០០ រៀល | ២០ថ្ងៃ | ៤ឆ្នាំ |
| ២៣ | ការផ្តល់លិខិតអនុញ្ញាតដល់មន្ទីរពហុព្យាបាល ចំពោះ ÷ | | | |
| | - ការបើកថ្មី | ៤ ៦០០ ០០០ រៀល | ២០ថ្ងៃ | ៤ឆ្នាំ |
| | -ការផ្ទេរអ្នកទទួលខុសត្រូវ | ២ ៣០០ ០០០ រៀល | ២០ថ្ងៃ | |
| | - ការប្តូរទីតាំង | ៣ ០០០ ០០០ រៀល | ២០ថ្ងៃ | ៤ឆ្នាំ |
| ២៤ | ការផ្តល់លិខិតអនុញ្ញាតដល់មន្ទីរពេទ្យឯកជន ចំពោះ ÷ | | | |
| | - ការបើកថ្មី | ៦ ០០០ ០០០ រៀល | ២០ថ្ងៃ | ៤ឆ្នាំ |
| | -ការផ្ទេរអ្នកទទួលខុសត្រូវ | ៣ ០០០ ០០០ រៀល | ២០ថ្ងៃ | |
| | - ការប្តូរទីតាំង | ៤ ០០០ ០០០ រៀល | ២០ថ្ងៃ | ៤ឆ្នាំ |
| ២៥ | ការផ្តល់លិខិតអនុញ្ញាតដល់មជ្ឈមណ្ឌលកែសម្ផស្ស ចំពោះ ÷ | | | |
| | - ការបើកថ្មី | ៦ ០០០ ០០០ រៀល | ២០ថ្ងៃ | ២ឆ្នាំ |
| | -ការផ្ទេរអ្នកទទួលខុសត្រូវ | ៣ ០០០ ០០០ រៀល | ២០ថ្ងៃ | ២ឆ្នាំ |
| | - ការប្តូរទីតាំង | ៤ ០០០ ០០០ រៀល | ២០ថ្ងៃ | ២ឆ្នាំ |

| ល.រ | បរិយាយ | តម្លៃឯកតា នៃសេវា | រយៈពេលអតិបរមា សម្រាប់ការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ២៦ | ការផ្តល់លិខិតអនុញ្ញាតដល់ការិយាល័យទំនាក់ទំនងសេវាសុខភាព ចំពោះ ÷ | | | |
| | - ការបើកថ្មី | ១ ០០០ ០០០ រៀល | ២០ថ្ងៃ | ២ឆ្នាំ |
| | -ការផ្ទេរអ្នកទទួលខុសត្រូវ | ៥០០ ០០០ រៀល | ២០ថ្ងៃ | |
| | - ការប្តូរទីតាំង | មិនគិតថ្លៃ | ២០ថ្ងៃ | |
| ២៧ | ការផ្តល់លិខិតអនុញ្ញាតឱ្យផ្សព្វផ្សាយពាណិជ្ជកម្មសម្រាប់ទីតាំងប្រកបអាជីវកម្មសេវាសុខភាព និងវេជ្ជបណ្ឌិត/ពេទ្យ/កែសម្ផស្ស | ៨០០ ០០០ រៀល | ២០ថ្ងៃ | ១ឆ្នាំ |
| ២៨ | ការផ្តល់លិខិតអនុញ្ញាតឱ្យចុះបញ្ជីការរថយន្តគិលានសង្គ្រោះឯកជន | ១០០ ០០០ រៀល | ៥ថ្ងៃ | ១ឆ្នាំ |
| ២៩ | អនុវត្តវិធានការសុខាភិបាល ដើម្បីទប់ស្កាត់ និងឆ្លើយតបការឆ្លងរាលដាលជាអន្តរជាតិនៃជំងឺនៅតាមច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ ឬ ទន្លេ (តាមការបែងចែកភារកិច្ចរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល) | | | |
| ២៩.១ | ចេញវិញ្ញាបនបត្រចត្តាឡីស័កក្រោយពេលត្រួតពិនិត្យលិខិតប្រកាសសុខភាពនិងការប្រកាសទូទៅចំពោះ អាកាសយានពេលចូល | ២០ ដុល្លារ | ១ថ្ងៃ | ១លើក |
| ២៩.២ | ចេញលិខិតអនុញ្ញាត (សេរីប្រតិបត្តិ) ក្រោយពេលត្រួតពិនិត្យលិខិតប្រកាសសុខភាព - លក្ខណៈអនាម័យទូទៅ ចំពោះនាវា ឬ សាឡាងចូល | ២០ ដុល្លារ | ១ថ្ងៃ | ដល់ពេលចេញដំណើរ |
| ២៩.៣ | ចេញវិញ្ញាបនបត្រអនុញ្ញាតក្រោយពេលត្រួតពិនិត្យលិខិតប្រកាសសុខភាព - លក្ខណៈអនាម័យទូទៅ ចំពោះនាវា ឬ សាឡាងចេញ | ២០ ដុល្លារ | ១ថ្ងៃ | រហូតដល់កំពង់ផែបន្ទាប់ |
| ២៩.៤ | ចេញវិញ្ញាបនបត្របញ្ជាក់ក្រោយពេលធ្វើអធិការកិច្ចអនាម័យទូទៅលើនាវា ឬ សាឡាងពេលអស់សុពលភាព | ១០០ ដុល្លារ | ២ថ្ងៃ | ៦ខែ |
| ២៩.៥ | ចេញវិញ្ញាបនបត្រអនុញ្ញាតឱ្យដឹកសាកសព ឬ អដ្ឋិធាតុ ឆ្លងដែនចេញ-ចូល | មិនគិតថ្លៃ | ១ថ្ងៃ | |
| ២៩.៦ | ចេញវិញ្ញាបនបត្រចត្តាឡីស័កក្រោយពេលត្រួតពិនិត្យសម្រាប់ការធ្វើចរាចរណ៍ចូលក្នុងប្រទេសចំពោះយានយន្តធុនធំ មានសណ្ដោងរ៉ឺម៉ក | ២៥ ០០០ រៀល | ភ្លាមៗ | ១លើក |

| ល.រ | បរិយាយ | តម្លៃឯកតានៃសេវា | រយៈពេលអតិបរមាសម្រាប់ការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ២៩.៧ | ចេញវិញ្ញាបនបត្រចត្តាឡីស័កក្រោយពេលត្រួតពិនិត្យសម្រាប់ការធ្វើចរាចរណ៍ចូលក្នុងប្រទេសចំពោះរថយន្តធំដែលមានចំណុះទម្ងន់៥តោនឡើង | ២០ ០០០ រៀល | ភ្លាមៗ | ១លើក |
| ២៩.៨ | ចេញវិញ្ញាបនបត្រចត្តាឡីស័កក្រោយពេលត្រួតពិនិត្យសម្រាប់ការធ្វើចរាចរណ៍ចូលក្នុងប្រទេសចំពោះរថយន្តធំដែលមានចំណុះទម្ងន់ក្រោម៥តោន | ១០ ០០០ រៀល | ភ្លាមៗ | ១លើក |
| ២៩.៩ | ចេញលិខិតបញ្ជាក់ការចាក់ថ្នាំបង្ការជំងឺអន្តរជាតិ (មិនគិត vaccin) តាមការស្នើសុំ | ៣ ដុល្លារ | ភ្លាមៗ | ១លើក |
| ២៩.១០ | ត្រួតពិនិត្យចត្តាឡីស័កលក្ខណៈសម្បត្តិអំពីសុវត្ថិភាព អនាម័យ ស្បៀងអាហារសម្រាប់នាវិកនិយោជិក (នាវា-កប៉ាល់) តាមការស្នើសុំ | ១០ ដុល្លារ | ២ថ្ងៃ | ១លើក |
| ២៩.១១ | កំចាត់សត្វកណ្តុរដោយចំហាយជាតិគីមីសាស្ត្រក្នុងនាវា-សាឡង់ (ករណីពិនិត្យឃើញជាក់ស្តែង) | ០,៨០ ដុល្លារ/$m^3$ | ១ថ្ងៃ | ១លើក |
| ២៩.១២ | កំចាត់សត្វល្អិត | | | |
| | - យន្តហោះដឹកមនុស្ស ចំណុះក្រោម ៣០០កៅអី (ករណីមានជំងឺ) | ៤០ ដុល្លារ/$m^3$ | ១ថ្ងៃ | ១លើក |
| | - យន្តហោះដឹកមនុស្ស ចំណុះចាប់ពី ៣០០ កៅអីឡើងទៅ (ករណីមានជំងឺ) | ៦០ ដុល្លារ/$m^3$ | ១ថ្ងៃ | ១លើក |
| | - យន្តហោះដឹកទំនិញគ្រប់ប្រភេទ (ករណីមានជំងឺ ឬ ជាប្រភពបង្ករោគ) | ៣០ ដុល្លារ/$m^3$ | ១ថ្ងៃ | ១លើក |
| | - យានដឹកជញ្ជូនផ្លូវគោកមានចំណុះទម្ងន់ចាប់ពី៥តោនឡើងទៅ (ករណីមានជំងឺ) | ២០ ០០០ រៀល | ១ថ្ងៃ | ១លើក |
| | - យានដឹកជញ្ជូនផ្លូវគោកមានចំណុះទម្ងន់ក្រោម៥តោន (ករណីមានជំងឺ) | ១០ ០០០ រៀល | ១ថ្ងៃ | ១លើក |
| | - នាវាសមុទ្រគ្រប់ប្រភេទ (ករណីមានជំងឺ ឬ មានការស្នើសុំ) | ០,៤០ ដុល្លារ/$m^3$ | ១ថ្ងៃ | ១លើក |
| | - នាវា- ទូកគ្រប់ប្រភេទ កប៉ាល់ដឹកមនុស្ស-ទំនិញ កប៉ាល់អូស-ទាញ (ករណីមានជំងឺ ឬ ការស្នើសុំ) | ០,៤០ ដុល្លារ/$m^3$ | ១ថ្ងៃ | ១លើក |
| | - ឃ្លាំងទំនិញ (តាមការស្នើសុំ) | ៤០០ រៀល/$m^3$ | ១ថ្ងៃ | ១លើក |
| | - កុងតឺន័រ ៤០ ហ្វីត (តាមការស្នើសុំ) | ៨០ ០០០ រៀល | ១ថ្ងៃ | ១លើក |
| | - កុងតឺន័រ ២០ ហ្វីត (តាមការស្នើសុំ) | ៥២ ០០០ រៀល | ១ថ្ងៃ | ១លើក |

| ល.រ | បរិយាយ | តម្លៃឯកតា នៃសេវា | រយៈពេលអតិបរមា សម្រាប់ការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ២៩.១៣ | ការរម្ងាប់មេរោគ | | | |
| | - រម្ងាប់មេរោគទឹកបាតកប៉ាល់- នាវាដែលកំពុងផ្ទុកទំនិញ/ចំណុះទម្ងន់ក្រោម ១០០០តោន (ករណីពិនិត្យឃើញមានភ្នាក់ងារចម្លងរោគជាក់ស្តែង) | ៤០ ដុល្លារ | ១ថ្ងៃ | ១លើក |
| | - រម្ងាប់មេរោគទឹកបាតកប៉ាល់- នាវាដែលកំពុងផ្ទុកទំនិញ/ចំណុះទម្ងន់ចាប់ពី ១០០០តោនឡើងទៅ (ករណីពិនិត្យឃើញមានភ្នាក់ងារចម្លងរោគជាក់ស្តែង) | ៦០ ដុល្លារ | ១ថ្ងៃ | ១លើក |
| | - រម្ងាប់មេរោគក្នុងកប៉ាល់ -ទូកគ្រប់ប្រភេទ (ករណីពិនិត្យឃើញមានភ្នាក់ងារចម្លងរោគជាក់ស្តែង) | ០,៥០ ដុល្លារ/$m^2$ | ១ថ្ងៃ | ១លើក |
| | - រម្ងាប់មេរោគក្នុងយន្តហោះគ្រប់ប្រភេទ (តាមការស្នើសុំ) | ០,៥០ ដុល្លារ/$m^2$ | ១ថ្ងៃ | ១លើក |
| | - រម្ងាប់មេរោគក្នុងឃ្លាំងដាក់កុងតឺន័រគ្រប់ប្រភេទ (តាមការស្នើសុំ) | ០,៣០ ដុល្លារ/$m^2$ | ១ថ្ងៃ | ១លើក |
| | - រម្ងាប់មេរោគក្នុងរថភ្លើង (បន្ទប់ទូរ,ក្បាលអូស) (តាមការស្នើសុំ) | ២០ ០០០ រៀល | ១ថ្ងៃ | ១លើក |
| | - រម្ងាប់មេរោគក្នុងយានដឹកជញ្ជូនផ្លូវគោកមានចំណុះទម្ងន់លើស ៣០ តោនឡើងទៅ (តាមការស្នើសុំ) | ១៥ ០០០ រៀល | ១ថ្ងៃ | ១លើក |
| | - រម្ងាប់មេរោគក្នុងយានដឹកជញ្ជូនផ្លូវគោកមានចំណុះទម្ងន់ចាប់ពី ៥តោន ដល់ ៣០ តោន (តាមការស្នើសុំ) | ១០ ០០០ រៀល | ១ថ្ងៃ | ១លើក |
| ៣០ | ការផ្តល់វិញ្ញាបនបត្រឱសថ (បញ្ជាក់អត្តសញ្ញាណឱសថ) | ១ ០០០ ០០០ រៀល | ៤០ថ្ងៃ | ២ឆ្នាំ |
| ៣១ | ការផ្តល់វិញ្ញាបនបត្រអនុញ្ញាតដាក់លក់ផលិតផលឱសថ ឱសថបំប៉នសុខភាព ឬ ផលិតផលបំប៉នសុខភាព ផលិតផលជំនួយសុខភាព ឱសថបូរាណ ឧបករណ៍បរិក្ខារពេទ្យ ប្រតិករ និងគ្រឿងសម្អាង | ៤០០ ០០០ រៀល | ៤០ថ្ងៃ | ២ឆ្នាំ |
| ៣២ | បណ្តុះបណ្តាលខ្លឹមសារ ស្តីពីការផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ ដល់បុគ្គលិកក្រុមហ៊ុននាំចូល និងលក់ផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ (តាមការស្នើសុំ) | ៨០ ០០០ រៀល/ម្នាក់ | តាមជាក់ស្តែង | អចិន្ត្រៃយ៍ |
| ៣៣ | បណ្តុះបណ្តាលអនាម័យ និងសុវត្ថិភាពចំណីអាហារ | | | |
| | - បណ្តុះបណ្តាលអនាម័យ និងសុវត្ថិភាពចំណីអាហារដល់ចុងភៅ អ្នកគ្រប់គ្រង អ្នកបំរើសេវាកម្មម្ហូបអាហារក្នុងភោជនីយដ្ឋាន-អាហារដ្ឋាន និងក្នុងសេវាធ្វើម្ហូបការ ម្ហូបបុណ្យ និងពិធីផ្សេងៗ | ៤០ ០០០ រៀល/ម្នាក់ | តាមជាក់ស្តែង | អចិន្ត្រៃយ៍ |
| | - បណ្តុះបណ្តាលអនាម័យ និងសុវត្ថិភាពចំណីអាហារដល់បុគ្គលិកសិប្បកម្ម-រោងចក្រផលិតចំណីអាហារ | ៤០ ០០០ រៀល/ម្នាក់ | តាមជាក់ស្តែង | អចិន្ត្រៃយ៍ |

| ល.រ | បរិយាយ | តម្លៃឯកតា នៃសេវា | រយៈពេលអតិបរមា សម្រាប់ការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ៣៤ | ការផ្តល់វិញ្ញាបនបត្របញ្ជាក់អនាម័យសម្រាប់ភោជនីយដ្ឋាន អាហារដ្ឋាន ក្រុមហ៊ុន/អាជីវកម្មដ្ឋានបម្រើសេវាម្ហូបអាហារតាមយន្តហោះ ពិធីមង្គលការ ពិធីបុណ្យ និងពិធីជប់លៀងផ្សេងៗ | | | |
| | - ការផ្តល់វិញ្ញាបនបត្រអនុវត្តគោលការណ៍អនាម័យល្អ ដល់អាហារដ្ឋានខ្នាតធំ (ស្ថិតក្នុងរោងចក្រ សហគ្រាស) | ៨០០ ០០០ រៀល | ២០ថ្ងៃ | ១ឆ្នាំ |
| | - ការផ្តល់វិញ្ញាបនបត្របញ្ជាក់អនាម័យដល់ ក្រុមហ៊ុន/អាជីវកម្មដ្ឋានបម្រើសេវាម្ហូបអាហារតាមពិធីមង្គលការ ពិធីបុណ្យ និងពិធីជប់លៀងផ្សេងៗ ចាប់ពី ៣០តុ ដល់ ៥០តុ | ៤០០ ០០០ រៀល | ២០ថ្ងៃ | ១ឆ្នាំ |
| | - ការផ្តល់វិញ្ញាបនបត្របញ្ជាក់អនាម័យដល់ ក្រុមហ៊ុន/អាជីវកម្មដ្ឋានបម្រើសេវាម្ហូបអាហារតាមពិធីមង្គលការ ពិធីបុណ្យ និងពិធីជប់លៀងផ្សេងៗ លើសពី ៥០តុឡើងទៅ ឬ ក្រុមហ៊ុន/អាជីវកម្មដ្ឋានបម្រើសេវាម្ហូបអាហារតាមយន្តហោះ | ៨០០ ០០០ រៀល | ២០ថ្ងៃ | ១ឆ្នាំ |
| | - ការផ្តល់វិញ្ញាបនបត្រអនុវត្តគោលការណ៍អនាម័យល្អដល់ក្រុមហ៊ុន/អាជីវកម្មដ្ឋានបម្រើសេវាម្ហូបអាហារតាមពិធីមង្គលការ ពិធីបុណ្យ និងពិធីជប់លៀងផ្សេងៗ លើសពី ៥០តុឡើងទៅ ឬ ក្រុមហ៊ុន/អាជីវកម្មដ្ឋានបម្រើសេវាម្ហូបអាហារតាមយន្តហោះ | ៨០០ ០០០ រៀល | ២០ថ្ងៃ | ១ឆ្នាំ |
| | - ការផ្តល់វិញ្ញាបនបត្រអនុវត្តគោលការណ៍អនាម័យល្អដល់សិប្បកម្ម-រោងចក្រផលិតចំណីអាហារ | ១ ០០០ ០០០ រៀល | ៤០ថ្ងៃ | ១ឆ្នាំ |
| ៣៥ | ការផ្តល់វិញ្ញាបនបត្រចុះបញ្ជិកាផលិតផលចំណីអាហារ ចំនួន ០១មុខ | ៨០០ ០០០ រៀល | ៩០ថ្ងៃ | ២ឆ្នាំ |
| ៣៦ | ការចេញវិញ្ញាបនបត្របញ្ជាក់សុខភាព ក្រៅពីគោលដៅធ្វើប័ណ្ណបើកបរ យានយន្តគ្រប់ប្រភេទ | ២០ ០០០ រៀល | ៣ថ្ងៃ | |
| ៣៧ | ផ្តល់លិខិតគាំទ្រដល់អង្គភាពក្រៅរដ្ឋាភិបាល (ចំពោះគម្រោងដែលមានថវិកាលើសពី ១ម៉ឺនដុល្លាអាម៉េរិក) | មិនគិតថ្លៃ | ១៥ថ្ងៃ | ១ឆ្នាំ |
| ៣៨ | ការផ្តល់លិខិតអនុញ្ញាតជូនគម្រោងសិក្សាស្រាវជ្រាវសុខភាពដែលទាក់ទងនឹងមនុស្ស | ១ ៦០០ ០០០ រៀល | ៩០ថ្ងៃ | ១ឆ្នាំ |
| ៣៩ | ការផ្តល់វិញ្ញាបនបត្របញ្ជាក់អនាម័យភោជនីយដ្ឋាន ឬអាហារដ្ឋាន ÷ | | | |
| | - ភោជនីយដ្ឋានខ្នាតធំ (ភោជនីយដ្ឋានប្រណិត និងភោជនីយដ្ឋាននៅក្នុងសណ្ឋាគារ) | ៦០០ ០០០ រៀល | ២០ថ្ងៃ | ១ឆ្នាំ |
| | - អាហារដ្ឋានខ្នាតធំ (ក្នុងរោងចក្រ) | ៦០០ ០០០ រៀល | ២០ថ្ងៃ | ១ឆ្នាំ |
| ៤០ | ការបង់ថ្លៃរបស់និស្សិតសម្រាប់រៀបចំការប្រឡងថ្នាក់ជាតិជ្រើសរើសនិស្សិតចូលរៀនកម្រិតបរិញ្ញាបត្រ និងបរិញ្ញាបត្ររង ក្នុងវិស័យសុខាភិបាល (និស្សិត ១នាក់) | ១២០ ០០០ រៀល | | |

| ល.រ | បរិយាយ | តម្លៃឯកតា នៃសេវា | រយៈពេលអតិបរមា សម្រាប់ការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ៤១ | ការបង់ថ្លៃរបស់និស្សិតសម្រាប់រៀបចំការប្រឡងចេញថ្នាក់ជាតិ ដើម្បីបញ្ចប់ការសិក្សារបស់និស្សិតកម្រិតបរិញ្ញាបត្រ និងបរិញ្ញាបត្ររងក្នុងវិស័យសុខាភិបាល (និស្សិត ១នាក់) | ១០០ ០០០ រៀល | | ១លើក |

**សេចក្តីបញ្ជាក់:**

-ការស្នើសុំបិទៈ គ្រឹះស្ថានផលិតឱសថ, ការិយាល័យតំណាងគ្រឹះស្ថានផលិតឱសថ, គ្រឹះស្ថានអាហារ័ណ ឱសថស្ថាន ឱសថ គ្រឿងសម្អាង, មជ្ឈមណ្ឌលថែរក្សាសម្ផស្ស, គ្រឹះស្ថានលក់ដុំឱសថ, គ្រឹះស្ថាននាំចេញ-នាំចូល-ចែកចាយឱសថ, មន្ទីរព្យាបាលមាត់-ធ្មេញ, មន្ទីរពិសោធន៍វេជ្ជសាស្ត្រ, មន្ទីរសម្ភព, មន្ទីរសម្រាកព្យាបាល, មន្ទីរពហុព្យាបាល, មន្ទីរពេទ្យឯកជន, មជ្ឈមណ្ឌលកែសម្ផស្ស, ការិយាល័យទំនាក់ទំនងសេវាសុខភាព។

-ការស្នើសុំឈប់ផ្សព្វផ្សាយពាណិជ្ជកម្មអំពីៈ ឱសថ ឬ ឱសថបុរាណ ឬ គ្រឿងសម្អាង ឬ ឱសថបំប៉នសុខភាព ឬ អាហារបំប៉នសុខភាព ឬ ឧបករណ៍បរិក្ខារពេទ្យ ឬ ប្រតិករ ឬ ផលិតផលជំនួយសុខភាពប្រើក្រៅខ្លួនមនុស្ស តាមទូរទស្សន៍ (ប៉ុស្តិ៍) ឬ វិទ្យុ ឬ TV Screen Show ឬ ទស្សនាវដ្តី ឬ សារព័ត៌មាន ឬ គេហទំព័រ ឬ បណ្តាញសង្គម ឬ ខិត្តប័ណ្ណ ឬ សិក្ខាសាលា ឬមធ្យោបាយដឹកជញ្ជូននានា ឬ តាមសម្ភារប្រើប្រាស់ ឬ តាមមធ្យោបាយផ្សេងទៀត។

-ការស្នើសុំលុបលេខទិដ្ឋាការ-បញ្ជិកា ឱសថ ឬ ឱសថបុរាណ ឬ ឱសថបំប៉នសុខភាព ឬ អាហារបំប៉នសុខភាព ឬ ឧបករណ៍បរិក្ខារពេទ្យ ឬ ប្រតិករ ឬ ផលិតផលជំនួយសុខភាពប្រើក្រៅខ្លួនមនុស្ស ឬ លេខប្រវេទន៍គ្រឿងសម្អាង ឬ បញ្ជីគ្រឹះស្ថានផលិតឱសថនៅបរទេស។ ចំពោះសេវាខាងលើនេះ ក្រសួងសុខាភិបាល នឹងផ្តល់ការអនុញ្ញាតជូនក្នុងរយៈពេល ១៥ថ្ងៃ ដោយឥតគិតថ្លៃឡើយ ។

-ការស្នើសុំបន្តសុពលភាព ចំពោះសេវាដែលបានកំណត់សុពលភាពដែលមានចែងក្នុងឧបសម្ព័ន្ធនេះ ក្រសួងសុខាភិបាល កំណត់យកតម្លៃសេវា ៧០% នៃតម្លៃសេវា ដែលបានកំណត់ក្នុងតារាងឧបសម្ព័ន្ធនេះ។ សុពលភាពបន្ត មានរយៈពេលស្មើនឹងសុពលភាពផ្តល់ជូនលើកដំបូងដែរ ។

ក្រសួងសុខាភិបាល

ឧបសម្ព័ន្ធ២ ភ្ជាប់នឹងប្រកាសរួមលេខ ...៣៧៥ប.. សហវ.ប្រក ចុះថ្ងៃទី.១៨..... ខែ.វិច្ឆិកា... ឆ្នាំ២០១៦

ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ ដោយក្រសួងសុខាភិបាល

ក្រុមទី១ សេវាសាធារណៈដែលអនុវត្តដោយមន្ទីរសុខាភិបាលរាជធានី ខេត្ត

| ល.រ | បរិយាយ | តម្លៃឯកតានៃសេវា | រយៈពេលអតិបរមាសម្រាប់ការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ១ | ការចេញវិញ្ញាបនបត្របញ្ជាក់សុខភាព | | | |
| | - ការពិនិត្យកាយសម្បទាចំពោះការស្នើសុំធ្វើប័ណ្ណបើកបរទោចក្រយានយន្តប្រភេទ ក | ១០ ០០០ រៀល | ៣ថ្ងៃ | |
| | - ការពិនិត្យកាយសម្បទាចំពោះការស្នើសុំធ្វើប័ណ្ណបើកបររថយន្តគ្រប់ប្រភេទ | ១០ ០០០ រៀល | ៣ថ្ងៃ | |
| | - ក្រៅពីចំណុចទាំងពីរខាងលើ | ២០ ០០០ រៀល | ៣ថ្ងៃ | |
| ២ | ការផ្តល់លិខិតអនុញ្ញាតឱ្យធ្វើសិក្ខាសាលា (ក្រៅពីផលិតផលចិញ្ចឹមកុមារ និងទារក) | មិនគិតថ្លៃ | ២០ថ្ងៃ | |
| ៣ | ការផ្តល់លិខិតអនុញ្ញាតដល់បន្ទប់ថែទាំជំងឺ ឬ បន្ទប់ពិនិត្យស្ត្រីមានផ្ទៃពោះ ឬ បន្ទប់ព្យាបាលដោយចលនា ឬ បន្ទប់ពិគ្រោះជំងឺទូទៅ ឬ បន្ទប់ពិគ្រោះព្យាបាលជំងឺមាត់ធ្មេញ ចំពោះ ÷ | | | |
| | - ការបើកថ្មី | ២០០ ០០០ រៀល | ៧ថ្ងៃ | ៣ឆ្នាំ |
| | - ការប្តូរទីតាំង | មិនគិតថ្លៃ | ៧ថ្ងៃ | ៣ឆ្នាំ |
| ៤ | ការផ្តល់លិខិតអនុញ្ញាតដល់ឱសថស្ថាន ចំពោះ ÷ | | | |
| | - ការបើកថ្មី | ៦០០ ០០០ រៀល | ១៥ថ្ងៃ | ២ឆ្នាំ |
| | - ការប្តូរទីតាំង | ៣០០ ០០០ រៀល | ១៥ថ្ងៃ | ២ឆ្នាំ |
| | - ប្តូរឈ្មោះឱសថការី ឬ ប្តូរឈ្មោះឱសថស្ថាន ឬ ប្តូរម្ចាស់ទុន | ៣០០ ០០០ រៀល | ១៥ថ្ងៃ | ២ឆ្នាំ |
| ៥ | ការផ្តល់លិខិតអនុញ្ញាតដល់ឱសថស្ថានរង "ក" ចំពោះ ÷ | | | |
| | - ការបើកថ្មី | ៤០០ ០០០ រៀល | ១៥ថ្ងៃ | ២ឆ្នាំ |
| | - ប្តូរឈ្មោះឱសថការី ឬ ប្តូរឈ្មោះឱសថស្ថាន ឬ ប្តូរម្ចាស់ទុន | ២០០ ០០០ រៀល | ១៥ថ្ងៃ | ២ឆ្នាំ |

| ល.រ | បរិយាយ | តម្លៃឯកតានៃសេវា | រយៈពេលអតិបរមាសម្រាប់ការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ៦ | ការបន្តសុពលភាពនិសថស្ថានរង "ខ" | ២០០ ០០០ រៀល | ១៥ថ្ងៃ | ២ឆ្នាំ |
| ៧ | ការផ្តល់លិខិតអនុញ្ញាតដល់អគារនិសថបុរាណ ចំពោះ ÷ | | | |
| | - ការបើកថ្មី | ៤០០ ០០០ រៀល | ១៥ថ្ងៃ | ១ឆ្នាំ |
| | - ការប្តូរទីតាំង | ២០០ ០០០ រៀល | ១៥ថ្ងៃ | ១ឆ្នាំ |
| | - ប្តូរឈ្មោះគ្រូនិសថបុរាណ ឬ ប្តូរឈ្មោះអគារលក់និសថបុរាណ ឬ ប្តូរម្ចាស់ទុន | ២០០ ០០០ រៀល | ១៥ថ្ងៃ | ១ឆ្នាំ |
| ៨ | ការផ្តល់វិញ្ញាបនបត្របញ្ជាក់អនាម័យ ភោជនីយដ្ឋាន និងអាហារដ្ឋាន | | | |
| | - ភោជនីយដ្ឋាន | ៣០០ ០០០ រៀល | ២០ថ្ងៃ | ១ឆ្នាំ |
| | - អាហារដ្ឋាន | ២០០ ០០០ រៀល | ២០ថ្ងៃ | ១ឆ្នាំ |
| ៩ | អនុវត្តវិធានការសុខាភិបាល ដើម្បីទប់ស្កាត់ និងឆ្លើយតបការឆ្លងរាលដាលជាអន្តរជាតិនៃជំងឺនៅតាមច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ ឬទន្លេ (តាមការបែងចែកភារកិច្ចរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល) | | | |
| ៩.១ | ចេញវិញ្ញាបនបត្រចត្តាឡីស័កក្រោយពេលត្រួតពិនិត្យលិខិតប្រកាសសុខភាពនិងការប្រកាសទូទៅចំពោះអាកាសយានពេលចូល | ២០ ដុល្លារ | ១ថ្ងៃ | ១លើក |
| ៩.២ | ចេញលិខិតអនុញ្ញាត (សេរីប្រតិបត្តិ) ដោយត្រួតពិនិត្យលិខិតប្រកាសសុខភាព - លក្ខណៈអនាម័យទូទៅ ចំពោះនាវា ឬ សាឡាងចូល | ២០ ដុល្លារ | ១ថ្ងៃ | ដល់ពេលចេញដំណើរ |
| ៩.៣ | ចេញវិញ្ញាបនបត្រអនុញ្ញាតក្រោយពេលត្រួតពិនិត្យលិខិតប្រកាសសុខភាព - លក្ខណៈអនាម័យទូទៅ ចំពោះនាវា ឬ សាឡាងចេញ | ២០ ដុល្លារ | ១ថ្ងៃ | រហូតដល់កំពង់ផែបន្ទាប់ |
| ៩.៤ | ចេញវិញ្ញាបនបត្រអនុញ្ញាតឱ្យដឹកសាកសព ឬ អដ្ឋិធាតុ ឆ្លងដែនចេញ-ចូល | មិនគិតថ្លៃ | ១ថ្ងៃ | |
| ៩.៥ | ចេញវិញ្ញាបនបត្រចត្តាឡីស័កក្រោយពេលត្រួតពិនិត្យសម្រាប់ការធ្វើចរាចរណ៍ចូលក្នុងប្រទេសចំពោះ[illegible]មានសណ្តោងរ៉ឺម៉ក | ២៥ ០០០ រៀល | ភ្លាមៗ | ១លើក |

| ល.រ | បរិយាយ | តម្លៃឯកតានៃសេវា | រយៈពេលអតិបរមាសម្រាប់ការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ៩.៦ | ចេញវិញ្ញាបនបត្រចត្តាឡីស័កក្រោយពេលត្រួតពិនិត្យសម្រាប់ការធ្វើចរាចរណ៍ចូលក្នុងប្រទេសចំពោះរថយន្តធំដែលមានចំណុះទម្ងន់៥តោនឡើង | ២០ ០០០ រៀល | ភ្លាមៗ | ១លើក |
| ៩.៧ | ចេញវិញ្ញាបនបត្រចត្តាឡីស័កក្រោយពេលត្រួតពិនិត្យសម្រាប់ការធ្វើចរាចរណ៍ចូលក្នុងប្រទេសចំពោះរថយន្តធំដែលមានចំណុះទម្ងន់ក្រោម៥តោន | ១០ ០០០ រៀល | ភ្លាមៗ | ១លើក |
| ៩.៨ | ចេញវិញ្ញាបនបត្រចត្តាឡីស័កក្រោយពេលត្រួតពិនិត្យសម្រាប់ការធ្វើចរាចរណ៍ចូលក្នុងប្រទេសចំពោះរថភ្លើង (គិតតាមបន្ទប់ទូរ, ក្បាលរថភ្លើង) | ៣ ដុល្លារ | ភ្លាមៗ | ១លើក |
| ៩.៩ | ត្រួតពិនិត្យចត្តាឡីស័កលក្ខណៈសម្បត្តិអំពីសុវត្ថិភាព អនាម័យ ស្បៀងអាហារសម្រាប់នាវិកនិយោជិក (នាវា-កប៉ាល់-យន្តហោះ-រថភ្លើង) តាមការស្នើសុំ | ១០ ដុល្លារ | ២ថ្ងៃ | ១លើក |
| ៩.១០ | កំចាត់សត្វល្អិត | | | |
| | - យន្តហោះដឹកមនុស្ស ចំណុះក្រោម ៣០០កៅអី (ករណីមានជំងឺ) | ៤០ ដុល្លារ/$m^3$ | ១ថ្ងៃ | ១លើក |
| | - យន្តហោះដឹកមនុស្ស ចំណុះចាប់ពី ៣០០ កៅអីឡើងទៅ (ករណីមានជំងឺ) | ៦០ ដុល្លារ/$m^3$ | ១ថ្ងៃ | ១លើក |
| | - យន្តហោះដឹកទំនិញគ្រប់ប្រភេទ (ករណីមានជំងឺ ឬ ជាប្រភពបង្កភេត) | ៣០ ដុល្លារ/$m^3$ | ១ថ្ងៃ | ១លើក |
| | - យានដឹកជញ្ជូនផ្លូវគោកមានចំណុះទម្ងន់ចាប់ពី៥តោនឡើងទៅ (ករណីមានជំងឺ) | ២០ ០០០ រៀល | ១ថ្ងៃ | ១លើក |
| | - យានដឹកជញ្ជូនផ្លូវគោកមានចំណុះទម្ងន់ក្រោម៥តោន (ករណីមានជំងឺ) | ១០ ០០០ រៀល | ១ថ្ងៃ | ១លើក |
| | - រថភ្លើង (ក្បាលរថភ្លើងគិតស្មើនឹងបន្ទប់ ឬ ទូរមួយ) (ករណីមានជំងឺ ឬ មានការស្នើសុំ) | ១០ ដុល្លារ | ១ថ្ងៃ | ១លើក |
| | - នាវាសមុទ្រគ្រប់ប្រភេទ (ករណីមានជំងឺ ឬ មានការស្នើសុំ) | ០,៤០ ដុល្លារ/$m^3$ | ១ថ្ងៃ | ១លើក |
| | - នាវា- ទូកគ្រប់ប្រភេទ កប៉ាល់ដឹកមនុស្ស-ទំនិញ កប៉ាល់អូស-ទាញ (ករណីមានជំងឺ ឬ ការស្នើសុំ) | ០,៤០ ដុល្លារ/$m^3$ | ១ថ្ងៃ | ១លើក |
| | - កុងតឺន័រ ៤០ ហ្វីត (តាមការស្នើសុំ) | ៨០ ០០០ រៀល | ១ថ្ងៃ | ១លើក |
| | - កុងតឺន័រ ២០ ហ្វីត (តាមការស្នើសុំ) | ៥២ ០០០ រៀល | ១ថ្ងៃ | ១លើក |

| ល.រ | បរិយាយ | តម្លៃឯកតានៃសេវា | រយៈពេលអតិបរមាសម្រាប់ការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ៩.១១ | ការរម្ងាប់មេរោគ | | | |
| | - រម្ងាប់មេរោគក្នុងកប៉ាល់-ទូកគ្រប់ប្រភេទ (ករណីពិនិត្យឃើញមានភ្នាក់ងារចម្លងរោគជាក់ស្តែង) | 0,៥០ ដុល្លារ/m³ | ១ថ្ងៃ | ១លើក |
| | - រម្ងាប់មេរោគក្នុងយន្តហោះគ្រប់ប្រភេទ (តាមការស្នើសុំ) | 0,៥០ ដុល្លារ/m³ | ១ថ្ងៃ | ១លើក |
| | - រម្ងាប់មេរោគក្នុងរថភ្លើង (បន្ទប់ទូរ, ក្បាលអូស) (តាមការស្នើសុំ) | ២០ ០០០ រៀល | ១ថ្ងៃ | ១លើក |
| | - រម្ងាប់មេរោគក្នុងយានដឹកជញ្ជូនផ្លូវគោកមានចំណុះទម្ងន់លើស ៣០ តោនឡើងទៅ (តាមការស្នើសុំ) | ១៥ ០០០ រៀល | ១ថ្ងៃ | ១លើក |
| | - រម្ងាប់មេរោគក្នុងយានដឹកជញ្ជូនផ្លូវគោកមានចំណុះទម្ងន់ចាប់ពី ៥ តោន ដល់ ៣០ តោន (តាមការស្នើសុំ) | ១០ ០០០ រៀល | ១ថ្ងៃ | ១លើក |

**សេចក្តីបញ្ជាក់:**

-ការស្នើសុំបិទៈ បន្ទប់ថែទាំជំងឺ ឬ បន្ទប់ពិនិត្យស្ត្រីមានផ្ទៃពោះ ឬ បន្ទប់ព្យាបាលដោយចលនា ឬ បន្ទប់ពិគ្រោះជំងឺទូទៅ ឬ បន្ទប់ពិគ្រោះព្យាបាលជំងឺមាត់ធ្មេញ ឬ និសថស្ថាន ឬ និសថស្ថានរង “ក” ឬ និសថស្ថានរង “ខ” មន្ទីរសុខាភិបាលនឹងផ្តល់ការអនុញ្ញាតជូនក្នុងរយៈពេល ១៥ថ្ងៃ ដោយឥតគិតថ្លៃឡើយ ។

-រាល់ការស្នើសុំបន្តសុពលភាព ឬ បន្តសេចក្តីសម្រេច ដែលមានក្នុងឧបសម្ព័ន្ធនេះ មន្ទីរសុខាភិបាលរាជធានី ខេត្ត កំណត់យកតម្លៃ ៧០% នៃតម្លៃសេវាដែលបានកំណត់ក្នុងតារាងឧបសម្ព័ន្ធនេះ។ សុពលភាពបន្ត មានរយៈពេលស្មើនឹងសុពលភាពផ្តល់ជូនដំបូងដែរ។

ឧបសម្ព័ន្ធ៣ ភ្ជាប់នឹងប្រកាសរួមលេខ.១៣៧៤.. សហវ.ប្រក ចុះថ្ងៃទី..១៤..... ខែ.វិច្ឆិកា..... ឆ្នាំ២០១៦

ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ ដោយក្រសួងសុខាភិបាល

ប្រភេទបទល្មើស និងកម្រិតទឹកប្រាក់ពិន័យ

ឯកតាគិត: រៀល

| ល.រ | បរិយាយ | កម្រិតទឹកប្រាក់ពិន័យអន្តរការណ៍ជាប្រាក់ ដោយក្រសួងសុខាភិបាល | | កម្រិតទឹកប្រាក់ពិន័យ អនុលោមតាមការសម្រេច របស់សាលាជម្រះក្តី |
|---|---|---|---|---|
| | | អនុវត្តដោយ រដ្ឋបាលកណ្តាល | អនុវត្តដោយមន្ទីរ សុខាភិបាលរាជធានី ខេត្ត | |
| I. ប្រភេទបទល្មើសដែលមានចែងក្នុងច្បាប់ ស្តីពីការប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ | | | | |
| ១ | មន្ទីរព្យាបាលជំងឺមាត់-ធ្មេញ ដែលពុំមានច្បាប់អនុញ្ញាត ឬ ហួសសុពលភាព (មាត្រា ៥) | ៥ ០០០ ០០០ | | |
| ២ | មន្ទីរពិសោធន៍វេជ្ជសាស្ត្រ ដែលពុំមានច្បាប់អនុញ្ញាត ឬ ហួសសុពលភាព (មាត្រា ៥) | ៥ ០០០ ០០០ | | |
| ៣ | មន្ទីរសម្ភព ដែលពុំមានច្បាប់អនុញ្ញាត ឬ ហួសសុពលភាព (មាត្រា ៥) | ៥ ០០០ ០០០ | | |
| ៤ | មន្ទីរសំភពព្យាបាល ដែលពុំមានច្បាប់អនុញ្ញាត ឬ ហួសសុពលភាព (មាត្រា ៥) | ៥ ០០០ ០០០ | | |
| ៥ | មន្ទីរពហុព្យាបាល ដែលពុំមានច្បាប់អនុញ្ញាត ឬ ហួសសុពលភាព (មាត្រា ៥) | ៥ ០០០ ០០០ | | |
| ៦ | មន្ទីរពេទ្យឯកជន ដែលពុំមានច្បាប់អនុញ្ញាត ឬ ហួសសុពលភាព (មាត្រា ៥) | ៥ ០០០ ០០០ | | |
| ៧ | មជ្ឈមណ្ឌលកែសម្ផស្ស ដែលពុំមានច្បាប់អនុញ្ញាត ឬ ហួសសុពលភាព (មាត្រា ៥) | ៥ ០០០ ០០០ | | |
| ៨ | ការិយាល័យទំនាក់ទំនងសេវាសុខភាព ដែលពុំមានច្បាប់អនុញ្ញាត ឬ ហួសសុពលភាព (មាត្រា ៥) | ៥ ០០០ ០០០ | | |
| ៩ | រថយន្តគិលានសង្គ្រោះឯកជន ដែលពុំមានចុះកិច្ចបញ្ជីកា ឬ ហួសសុពលភាព (មាត្រា ៥) | ៥ ០០០ ០០០ | | |

| ល.រ | បរិយាយ | កម្រិតទឹកប្រាក់ពិន័យអន្តរការណ៍ជាប្រាក់ ដោយក្រសួងសុខាភិបាល | | កម្រិតទឹកប្រាក់ពិន័យ អនុលោមតាមការសម្រេច របស់សាលាជម្រះក្តី |
|---|---|---|---|---|
| | | អនុវត្តដោយ រដ្ឋបាលកណ្តាល | អនុវត្តដោយមន្ទីរ សុខាភិបាលរាជធានី ខេត្ត | |
| ១០ | ការប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ ខុសឯកទេស ឬ ជំនាញដែលបានចុះឈ្មោះក្នុងបញ្ជីសមាជិកគណៈគ្រូពេទ្យ គណៈឱសថការី គណៈទន្តពេទ្យ គណៈឆ្មប គណៈគិលានុប្បដ្ឋាក (មាត្រា ៦) | ៥ ០០០ ០០០ | | |
| ១១ | មន្ទីរសម្ភព មន្ទីរសំរាកព្យាបាល មន្ទីរពហុព្យាបាល មន្ទីរពេទ្យឯកជន ដែលមានគ្រែសម្រាប់អ្នកជំងឺសម្រាកព្យាបាល និងមន្ទីរពិសោធន៍ឯកជន ដែលគ្មានវត្តមានរបស់អ្នកទទួលខុសត្រូវដែលកំណត់ដោយប្រកាសរបស់ក្រសួងសុខាភិបាល ឬ ករណីអវត្តមានអ្នកទទួលខុសត្រូវ គ្មានអ្នកជំនួសដែលកំណត់ដោយប្រកាសរបស់ក្រសួងសុខាភិបាល (មាត្រា ៧) | ៥ ០០០ ០០០ | | |
| ១២ | អ្នកវេជ្ជសាស្ត្រ អ្នកអមវេជ្ជសាស្ត្រ ឬ អ្នកជំនួយវេជ្ជសាស្ត្រមួយរូប ដែលបើកសេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ ឬ អ្នកជំនួយវេជ្ជសាស្ត្រឯកជនរបស់ខ្លួនលើសពីមួយកន្លែង ទោះមានសញ្ញាប័ត្រឯកទេសច្រើនក្តី (មាត្រា ៨) | ៥ ០០០ ០០០ | | |
| ១៣ | ការផ្សព្វផ្សាយពាណិជ្ជកម្មតាមវិទ្យុ ទូរទស្សន៍ ទស្សនាវដ្តី សារព័ត៌មាន ខិតប័ណ្ណ សិក្ខាសាលា ឬ តាមមធ្យោបាយផ្សេងៗទៀត សម្រាប់ឃោសនាសេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ ឬ អ្នកជំនួយវេជ្ជសាស្ត្រឯកជនដែលពុំមានការអនុញ្ញាត ឬ សុំបន្តសុពលភាពពីក្រសួងសុខាភិបាល (មាត្រា ១១) | ៥ ០០០ ០០០ | | |

| ល.រ | បរិយាយ | កម្រិតទឹកប្រាក់ពិន័យអន្តរការណ៍ជាប្រាក់ ដោយក្រសួងសុខាភិបាល | | កម្រិតទឹកប្រាក់ពិន័យ អនុលោមតាមការសម្រេច របស់សាលាជម្រះក្តី |
|---|---|---|---|---|
| | | អនុវត្តដោយ រដ្ឋបាលកណ្តាល | អនុវត្តដោយមន្ទីរ សុខាភិបាលរាជធានី ខេត្ត | |
| ១៤ | ការរារាំងសមត្ថកិច្ចរបស់ក្រសួងសុខាភិបាល ក្នុងការបំពេញភារកិច្ចអធិការកិច្ចរបស់ខ្លួន ក្នុងការពង្រឹងគុណភាពសេវាកម្មប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ (មាត្រា ១៤) | ១០ ០០០ ០០០ | | |
| **II. ប្រភេទបទល្មើសដែលមានចែងក្នុងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងឱសថ** | | | | |
| ១៥ | ការផ្សព្វផ្សាយផលិតផលឱសថ និងគ្រឿងសម្អាង តាមវិទ្យុ ទូរទស្សន៍ ទស្សនាវដ្តី សារព័ត៌មាន ខិតប័ណ្ណ សិក្ខាសាលា ឬ តាមមធ្យោបាយផ្សេងៗទៀត (គេហទំព័រ ឬ បណ្តាញសង្គម Facebook ឬ ព្រឹត្តប័ត្រវេជ្ជសាស្ត្រ-ឱសថសាស្ត្រ-ទន្តសាស្ត្រ ឬ ប័ណ្ណរូបភាព ឬ សម្ភារៈការិយាល័យ ឬ ឃោសនាសព្ទ ឬ ការប្រគុំតន្ត្រី ឬ ទិវាវេជ្ជសាស្ត្រ-ឱសថសាស្ត្រ-ទន្តសាស្ត្រ ...) ដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល (មាត្រា ១០ ថ្មី) | ១ ៥០០ ០០០ | ១ ៥០០ ០០០ | |
| ១៦ | ការប្រព្រឹត្តល្មើសនឹងបែបបទ និងល័ក្ខខ័ណ្ឌការគ្រប់គ្រងថែរក្សាផលិតផលឱសថ (មាត្រា ១០ ថ្មី) | ៥ ០០០ ០០០ | ៥ ០០០ ០០០ | |
| ១៧ | ការបើក បិទ ឬ ប្តូរទីតាំងឱសថស្ថាន ឱសថស្ថានរង ដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល (មាត្រា ១០ ថ្មី) | ២ ០០០ ០០០ | ២ ០០០ ០០០ | |

| ល.រ | បរិយាយ | កម្រិតទឹកប្រាក់ពិន័យអន្តរការណ៍ជាប្រាក់ ដោយក្រសួងសុខាភិបាល | | កម្រិតទឹកប្រាក់ពិន័យ អនុលោមតាមការសម្រេច របស់សាលាជម្រះក្តី |
|---|---|---|---|---|
| | | អនុវត្តដោយ រដ្ឋបាលកណ្តាល | អនុវត្តដោយមន្ទីរ សុខាភិបាលរាជធានី ខេត្ត | |
| ១៨ | ការបើក បិទ ឬ ប្តូរទីតាំងគ្រឹះស្ថានលក់ដុំឱសថ គ្រឹះស្ថាននាំចូល ចែកចាយឱសថ គ្រឹះស្ថាននាំចូល នាំចេញឱសថ គ្រឹះស្ថាននាំចូល នាំចេញគ្រឿងសម្អាង ដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល (មាត្រា ១០ថ្មី) | ៥ ០០០ ០០០ | | |
| ១៩ | ការប្រព្រឹត្តល្មើសនឹងបែបបទ និងល័ក្ខខ័ណ្ឌពាណិជ្ជកម្ម អាហារ៍ណ នីហារ៍ណឱសថ (មាត្រា ១០ ថ្មី) | ៥ ០០០ ០០០ | | |
| ២០ | ការនាំចូល នាំចេញផលិតផលឱសថ ដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល (មាត្រា ១០ ថ្មី) | ៥ ០០០ ០០០ | | |
| ២១ | ការចែកចាយ តាំងលក់ ឬ លក់ផលិតផលឱសថ គ្រឿងសម្អាងដោយគ្មានចុះលេខទិដ្ឋាការ ឬ បញ្ជិកា ឬ ប្រវេទន៍ ពីក្រសួងសុខាភិបាល (មាត្រា ១០ ថ្មី) | ៥ ០០០ ០០០ | | |
| ២២ | ការលក់ឱសថខូចគុណភាព និងឱសថផុតកំណត់ប្រើប្រាស់ (មាត្រា ១០ ថ្មី) | ៥ ០០០ ០០០ | | |
| ២៣ | ការបើក បិទ ឬ ប្តូរទីតាំងគ្រឹះស្ថានផលិតឱសថដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល (មាត្រា ១០ ថ្មី) | ១០ ០០០ ០០០ | | ពី ១០ ០០០ ០០០ ដល់ ២០ ០០០ ០០០ |
| ២៤ | ការប្រព្រឹត្តល្មើសបែបបទ និងល័ក្ខខ័ណ្ឌបច្ចេកទេសផលិតឱសថ (មាត្រា ១០ ថ្មី)។ | ១០ ០០០ ០០០ | | ពី ១០ ០០០ ០០០ ដល់ ២០ ០០០ ០០០ |
| ២៥ | ការនាំចូលវត្ថុធាតុដើម ផលិតផលពាក់កណ្តាលសម្រេច សម្ភារៈវេចខ្ចប់ ម៉ាស៊ីន ឧបករណ៍ សម្រាប់ផលិតឱសថ ដោយគ្មានច្បាប់អនុញ្ញាតពីក្រសួងសុខាភិបាល (មាត្រា ១០ថ្មី) | ១០ ០០០ ០០០ | | ពី ១០ ០០០ ០០០ ដល់ ២០ ០០០ ០០០ |

| ល.រ | បរិយាយ | កម្រិតទឹកប្រាក់ពិន័យអន្តរការណ៍ជាប្រាក់ ដោយក្រសួងសុខាភិបាល | | កម្រិតទឹកប្រាក់ពិន័យ អនុលោមតាមការសម្រេច របស់សាលាជម្រះក្តី |
|---|---|---|---|---|
| | | អនុវត្តដោយ រដ្ឋបាលកណ្តាល | អនុវត្តដោយមន្ទីរ សុខាភិបាលរាជធានី ខេត្ត | |
| ២៦ | ការផលិតឱសថដែលមានគុណភាព មិនត្រឹមត្រូវតាមស្តង់ដារគុណភាព ក្នុងឯកសារសុំទិដ្ឋាការឱសថ (មាត្រា ១០ថ្មី) | ១០ ០០០ ០០០ | | ពី ១០ ០០០ ០០០ ដល់ ២០ ០០០ ០០០ |
| ២៧ | ការស្តុកវត្ថុធាតុដើម ឬ សម្ភារៈវេចខ្ចប់ ម៉ាស៊ីនឧបករណ៍ផលិតឱសថ ក្រៅពីគ្រឹះស្ថានអាជីវកម្ម ផលិតកម្មដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល (មាត្រា ១០ថ្មី) | ១០ ០០០ ០០០ | | ពី ១០ ០០០ ០០០ ដល់ ២០ ០០០ ០០០ |
| ២៨ | ជនណារារាំងប្រឆាំងនឹងការអនុវត្តច្បាប់ ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងឱសថ (មាត្រា ១១ថ្មី) | ៥ ០០០ ០០០ | | ពី ២ ០០០ ០០០ ដល់ ១០ ០០០ ០០០ |
| ២៩ | ការផលិត នាំចូល ឬ ស្តុកឱសថញៀន ឬ ឱសថប្រព័ន្ធសរសៃប្រសាទសារធាតុផ្សំគ្រឿងញៀន ដែលកំណត់ក្នុងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឬ ក្នុងប្រកាសរបស់ក្រសួងសុខាភិបាល ដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល (មាត្រា ១២ ថ្មី) | ៣៥ ០០០ ០០០ | | ពី ២០ ០០០ ០០០ ដល់ ៥០ ០០០ ០០០ |
| ៣០ | ការចែកចាយ តាំងលក់ ឬ លក់ឱសថញៀន ឬ ឱសថប្រព័ន្ធសរសៃប្រសាទដែលគ្មានប្រយោជន៍ខាងវេជ្ជសាស្ត្រ ឬ ដែលក្រសួងសុខាភិបាលបានហាមឃាត់ (មាត្រា ១២ ថ្មី) | ៣៥ ០០០ ០០០ | | ពី ២០ ០០០ ០០០ ដល់ ៥០ ០០០ ០០០ |
| ៣១ | ផលិត ឬ នាំចូល ឬ ចែកចាយ ឬ តាំងលក់នូវឱសថក្លែងក្លាយ (មាត្រា ១២ ថ្មី) | ៣៥ ០០០ ០០០ | | ពី ២០ ០០០ ០០០ ដល់ ៥០ ០០០ ០០០ |
| III. ប្រភេទបទល្មើសដែលមានចែងក្នុងអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពី[illegible]ទប់ស្កាត់ និងឆ្លើយតបការឆ្លងរាលដាលជាអន្តរជាតិនៃជំងឺនៅតាមច្រកចេញចូល | | | | |
| ៣២ | អ្នកធានាអះអាងមិនឱ្យអ្នកដំណើរបំពេញលើលិខិតប្រកាសសុខភាពចូល ក្នុងករណីមានការផ្ទុះជំងឺឆ្លង (មាត្រា ទី៨) | ៤០០ ០០០ | ៤០០ ០០០ | |

| ល.រ | បរិយាយ | កម្រិតទឹកប្រាក់ពិន័យអន្តរការណ៍ជាប្រាក់ ដោយក្រសួងសុខាភិបាល | | កម្រិតទឹកប្រាក់ពិន័យ អនុលោមតាមការសម្រេច របស់សាលាជម្រះក្តី |
|---|---|---|---|---|
| | | អនុវត្តដោយ រដ្ឋបាលកណ្តាល | អនុវត្តដោយមន្ទីរ សុខាភិបាលរាជធានី ខេត្ត | |
| ៣៣ | មេបញ្ជាការនាវា- ឡង់មិនលើកទង់លឿងជាសញ្ញាសម្រាប់មន្ត្រីចត្តាឡីស័កត្រួតពិនិត្យស្ថានភាព និងវិនិច្ឆ័យលើលក្ខណៈអនាម័យទូទៅនៃនាវាមុនពេលធ្វើបែបបទចូល (មាត្រា ៨) | ២០០ ០០០ | ២០០ ០០០ | |
| ៣៤ | មេបញ្ជាការ នាវា- សាឡង់ដែលមិនអនុញ្ញាតឱ្យត្រួតពិនិត្យលិខិតវិនិច្ឆ័យលក្ខណៈអនាម័យទូទៅ ករណីផុតសុពលភាព | ១ ០០០ ០០០ | ១ ០០០ ០០០ | |
| ៣៥ | ម្ចាស់មធ្យោបាយដឹកជញ្ជូន ឬ បុគ្គលដែលនាំមធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទចូលព្រះរាជាណាចក្រកម្ពុជា ដោយគេចវេះពីការត្រួតពិនិត្យចត្តាឡីស័ក ឬ មិនបំពេញលើសេចក្តីប្រកាសសុខភាពពេលចូល (មាត្រា ទី៨) | ៥០០ ០០០ | ៥០០ ០០០ | |
| ៣៦ | ករណីផ្ទុះជំងឺឆ្លងហើយការីនៃយានដឹកជញ្ជូនគ្រប់ប្រភេទ គេចវេះមិនឱ្យធ្វើប្រព្រឹត្តកម្មវេជ្ជសាស្ត្រ | ៨០០ ០០០ | ៨០០ ០០០ | |
| ៣៧ | ការីនៃយានដឹកជញ្ជូនលាក់បាំង ឬ មិនរាយការណ៍ករណីមានជំងឺឆ្លងកើតឡើងនៅលើយាន (មាត្រា ៨) | ១ ០០០ ០០០ | ១ ០០០ ០០០ | |
| IV. **ប្រភេទបទល្មើសផ្សេងៗ ដែលពុំមានចែងក្នុងច្បាប់ និងអនុក្រឹត្យ តែដើម្បីពង្រឹងការគ្រប់គ្រងរបស់ក្រសួងសុខាភិបាល** | | | | |
| ៣៨ | ការផ្សព្វផ្សាយបំភ្លើសពីការពិតអំពីគុណភាព ប្រសិទ្ធិភាពលើការព្យាបាលជំងឺ ឬ ការការពារ ថែទាំ និងបំប៉នសុខភាព ឬ សម្រស់ នៃឱសថសម័យ ឬ ឱសថ បុរាណ ឬ ឱសថបំប៉នសុខភាព ឬ អាហារបំប៉នសុខភាព ឬ គ្រឿងសម្អាង ឬ ឧបករណ៍បរិក្ខាពេទ្យ ដែលបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរដល់សុខភាពមនុស្ស | ៥ ០០០ ០០០ | [illegible] | |

| ល.រ | បរិយាយ | កម្រិតទឹកប្រាក់ពិន័យអន្តរការណ៍ជាប្រាក់ ដោយក្រសួងសុខាភិបាល | | កម្រិតទឹកប្រាក់ពិន័យ អនុលោមតាមការសម្រេច របស់សាលាជម្រះក្តី |
|---|---|---|---|---|
| | | អនុវត្តដោយ រដ្ឋបាលកណ្តាល | អនុវត្តដោយមន្ទីរ សុខាភិបាលរាជធានី ខេត្ត | |
| ៣៩ | ការបើក ឬ ប្តូរទីតាំងគ្រឹះស្ថានអាហារ៍ណ នីហារ៍ណឱសថ ឧបករណ៍ បរិក្ខារពេទ្យ ប្រតិករមន្ទីរពិសោធន៍ មជ្ឈមណ្ឌលថែរក្សាសម្ផស្ស ដោយគ្មានច្បាប់អនុញ្ញាតពីក្រសួងសុខាភិបាល | ៥ ០០០ ០០០ | | |
| ៤០ | ការផ្លាស់ប្តូរ ឬ បន្ថែមខ្សែសង្វាក់ផលិតកម្មគ្រឹះស្ថានផលិតឱសថ ឬ សាខាគ្រឹះស្ថានផលិតឱសថ ឬ ឃ្លាំងស្តុក ឬ មន្ទីរពិសោធន៍គុណភាពឱសថ ដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល | ៥ ០០០ ០០០ | | |
| ៤១ | ការប្រព្រឹត្តល្មើសនឹងបែបបទ ឬលក្ខខណ្ឌពាណិជ្ជកម្ម ឬបទដ្ឋានគតិយុត្តិផ្សេងៗ ក្នុងការប្រកបអាជីវកម្មឱសថ | ២ ០០០ ០០០ | | |
| ៤២ | លិខិតអនុញ្ញាតឱ្យបើក ឬបន្តសុពលភាពឱសថស្ថាន ឱសថស្ថានរង ឬ អគារលក់ឱសថបុរាណ ដែលហួសសុពលភាពលើសពី ៣ខែ | ៨០០ ០០០ | ៨០០ ០០០ | |
| ៤៣ | លិខិតអនុញ្ញាតឱ្យបើក ឬបន្តសុពលភាពគ្រឹះស្ថានអាហារ៍ណ នីហារ៍ណឱសថ ឬ គ្រឿងសម្អាង ឬ គ្រឹះស្ថានលក់ដុំឱសថ ឬ មជ្ឈមណ្ឌលថែរក្សាសម្ផស្ស ហួសសុពលភាពលើសពី ៣ខែ | ៨០០ ០០០ | | |
| ៤៤ | លិខិតអនុញ្ញាតឱ្យបើក ឬបន្តសុពលភាពគ្រឹះស្ថានផលិតឱសថដែលហួសសុពលភាពលើសពី ៣ខែ | ១ ៥០០ ០០០ | | |
| ៤៥ | ការបើក បិទ ឬ ប្តូរទីតាំងលក់ឱសថបុរាណ ដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល | ១ ០០០ ០០០ | ១ ០០០ ០០០ | |

| ល.រ | បរិយាយ | កម្រិតទឹកប្រាក់ពិន័យអន្តរការណ៍ជាប្រាក់ ដោយក្រសួងសុខាភិបាល | | កម្រិតទឹកប្រាក់ពិន័យ អនុលោមតាមការសម្រេច របស់សាលាជម្រះក្តី |
|---|---|---|---|---|
| | | អនុវត្តដោយ រដ្ឋបាលកណ្តាល | អនុវត្តដោយមន្ទីរ សុខាភិបាលរាជធានី ខេត្ត | |
| ៤៦ | ការផ្សព្វផ្សាយផលិតផលឱសថ និងគ្រឿងសម្អាង តាមវិទ្យុ ទូរទស្សន៍ ទស្សនាវដ្តី សារព័ត៌មាន ខិតប័ណ្ណ សិក្ខាសាលា ឬ តាមមធ្យោបាយផ្សេងៗទៀត (គេហទំព័រ ឬ បណ្តាញសង្គម Facebook ឬ ព្រឹត្តិប័ត្រវេជ្ជសាស្ត្រ-ឱសថសាស្ត្រ-ទន្តសាស្ត្រ ឬ ប័ណ្ណរូបភាព ឬ សម្ភារៈការិយាល័យ ឬ ឃោសនាសព្ទ ឬ ការប្រគុំតន្ត្រី ឬ ទិវាវេជ្ជសាស្ត្រ-ឱសថសាស្ត្រ-ទន្តសាស្ត្រ ...) មិនត្រឹមត្រូវតាមខ្លឹមសារអនុញ្ញាតពីក្រសួងសុខាភិបាល | ១ ៥០០ ០០០ | ១ ៥០០ ០០០ | |
| ៤៧ | បន្ទប់ពិគ្រោះស្ត្រីមានផ្ទៃពោះ ដែលពុំមានច្បាប់អនុញ្ញាត ឬ ហួសសុពលភាព | | ១ ០០០ ០០០ | |
| ៤៨ | បន្ទប់ថែទាំអ្នកជំងឺ ដែលពុំមានច្បាប់អនុញ្ញាត ឬ ហួសសុពលភាព | | ១ ០០០ ០០០ | |
| ៤៩ | បន្ទប់ព្យាបាលដោយចលនា ដែលពុំមានច្បាប់អនុញ្ញាត ឬ ហួសសុពលភាព | | ១ ០០០ ០០០ | |
| ៥០ | បន្ទប់ពិគ្រោះព្យាបាលជំងឺទូទៅ ដែលពុំមានច្បាប់អនុញ្ញាត ឬ ហួសសុពលភាព | | ១ ០០០ ០០០ | |
| ៥១ | បន្ទប់ពិគ្រោះព្យាបាលជំងឺមាត់ធ្មេញ ដែលពុំមានច្បាប់អនុញ្ញាត ឬ ហួសសុពលភាព | | ១ ០០០ ០០០ | |
| ៥២ | ករណីរំលោភលើខ្លឹមសារអនុក្រឹត្យ ១៣៣ ស្តីពីការ ផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ ឬ មិនគោរពតាមខ្លឹមសារលិខិតអនុញ្ញាត របស់ក្រសួងសុខាភិបាល | ២ ៥០០ ០០០ | | |

**សេចក្តីបញ្ជាក់:**

-ក្នុងករណីពុំរាងចាលត្រូវអនុវត្តការពិន័យទ្វេដង ចំពោះប្រភេទបទល្មើសចាប់ពីលេខរៀងទី១ ដល់លេខរៀងទី១៣ នៃតារាងឧបសម្ព័ន្ធ

-ចំពោះការប្រព្រឹត្តបទល្មើសពាក់ព័ន្ធនឹងការហួសសុពលភាពនៃលិខិតអនុញ្ញាត អាចមានសិទ្ធិស្នើសុំបន្តសុពលភាពឡើងវិញបាន បន្ទាប់ពីអ្នកប្រព្រឹត្តបានបង់ប្រាក់ពិន័យរួច។